រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩

# សេចក្តីថ្លែងការណ៍នៃវេទិកាប្រជាពលរដ្ឋកម្ពុជា ២០១៩
# "ពង្រឹងសំឡេងប្រជាជន និងសាមគ្គីភាព"

យើងដែលជាប្រជាពលរដ្ឋមកពីសហគមន៍ ដីធ្លី ព្រៃឈើ នេសាទ កសិករ ជនជាតិដើមភាគតិច អ្នកការពារ សិទ្ធិមនុស្ស អ្នកការពារបរិស្ថាន សមាគម អង្គការមិនមែនរដ្ឋាភិបាល គ្រូបង្រៀន មន្ត្រីរាជការ សហជីព កម្មករ កម្មការិនី សកម្មជនស្ត្រី អ្នកប្រកបរបរផ្លូវភេទ ក្រុមអ្នកស្រលាញ់ភេទដូចគ្នា អ្នកមានពិការភាព យុវជន សិល្បករ អ្នកសម្តែង អ្នកកសាងសន្តិភាព និងប្រជាពលរដ្ឋមូលដ្ឋាន សរុបចំនួន២៦៨នាក់ ក្នុងនោះមានស្ត្រីចំនួន៥០% (១៣៩នាក់) បានរួមគ្នាធ្វើវេទិកាប្រជាពលរដ្ឋកម្ពុជាកាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សា បញ្ហាប្រឈម ក្តីកង្វល់ដែលពួកយើងកំពុងជួបប្រទះ ព្រមទាំងកំណត់បញ្ហា និងតម្រូវការអាទិភាពរបស់ពួកយើង និងប្រមូលសេចក្តីស្នើកែលម្អ ក៏ដូចជាមតិស្ថាបនា និងអនុសាសន៍ ដាក់ជូនដល់អ្នកតាក់តែង អ្នកអនុវត្តគោលនយោបាយ និងប្រមុខថ្នាក់ដឹកនាំទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ឲ្យបានជ្រាប និងរកដំណោះស្រាយចំពោះបញ្ហាទាំងនោះ ដើម្បីធានាថា ប្រទេសកម្ពុជាអាចបំពេញនូវស្មារតីសហការរបស់អាស៊ាន ពង្រឹងភាពជាដៃគូដើម្បីធានាឲ្យមាននិរន្តរភាព គ្រប់ជ្រុងជ្រោយ រក្សាបាននូវប្រយោជន៍ប្រជាជាតិអាស៊ានដើម្បីឲ្យសម្រេចបាន នូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

ខាងក្រោមនេះគឺជាបញ្ហាប្រឈម កង្វល់ចំបងៗ សេចក្តីស្នើកែលម្អ និងមតិស្ថាបនាដែលពួកយើងបានលើក នៅក្នុងវេទិកាប្រជាពលរដ្ឋកម្ពុជានេះ និងចង់ទទួលបានដំណោះស្រាយនៅឆ្នាំ ២០១៩-២០២០៖

## I. បញ្ហាប្រឈម និងកង្វល់ធំៗពាក់ព័ន្ធស្ថានភាពសិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងការទទួលបានយុត្តិធម៌

១. សិទ្ធិសេរីភាពមូលដ្ឋានរបស់ប្រជាពលរដ្ឋកម្ពុជាកំពុងត្រូវបានរឹតត្បិតយ៉ាងខ្លាំង។ រដ្ឋាភិបាលមានការយកចិត្តទុកដាក់ខ្ពស់លើតែការអភិវឌ្ឍន៍សេដ្ឋកិច្ច ប៉ុន្តែមិនបានខិតខំអនុវត្តឲ្យមានប្រសិទ្ធិភាពនូវ យន្តការធានាការគោរពសិទ្ធិសេរីភាពមូលដ្ឋានរបស់ប្រជាពលរដ្ឋទេ។ ការចូលរួមសកម្មភាពសង្គម ដែលឆ្លុះបញ្ចាំងពីការអនុវត្តសិទ្ធិសេរី ភាពរួមមាន សិទ្ធិបញ្ចេញមតិ សិទ្ធិជួបប្រជុំដោយសន្តិវិធី សិទ្ធិទទួលបានយុត្តិធម៌ សិទ្ធិដើរហើរ របស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ត្រូវបានជ្រៀតជ្រែក និងរារាំងដោយអាជ្ញាធរ។

២. ស្ថានភាពប្រជាធិបតេយ្យនៅកម្ពុជាកំពុងធ្លាក់ចុះ ជាពិសេសការអនុវត្តសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោតរបស់ពលរដ្ឋកំពុងរងការរឹតត្បិត។ ការបោះឆ្នោតចុងក្រោយត្រូវបានវាយតម្លៃមិនមានបរិយាកាសប្រកួតប្រជែងផ្នែកនយោបាយ។ សំឡេងរបស់ប្រជាពលរដ្ឋមិនត្រូវបានលើកកម្ពស់ក្នុងការពិចារណា និងដាក់បញ្ចូលក្នុងដំណើរការរៀបចំគោលនយោបាយ និងច្បាប់។ ការអនុវត្តដំណើរការ

ប្រជាធិបតេយ្យមិនបានពេញលេញធ្វើឲ្យប្រជាពលរដ្ឋមិនទទួលបាននូវផលអភិវឌ្ឍន៍ប្រកបដោយសមភាពនោះឡើយ។

៣. និទណ្ឌភាពនៅតែបន្តកើតមានក្នុងសង្គម ហើយឯករាជ្យភាពតុលាការក្នុងការផ្តល់សេវាយុត្តិធម៌ដល់ប្រជាពលរដ្ឋនៅតែបន្តធ្លាក់ចុះ ដោយសារអំពើពុករលួយ និងការជ្រៀតជ្រែកអំណាចតុលាការដែលធ្វើឲ្យប្រជាពលរដ្ឋសាមញ្ញ មានជីវភាពក្រីក្រ និងជនងាយរងគ្រោះ រងការរំលោភបំពាន ពីសំណាក់អ្នកមានធនធាន និងអ្នកមានអំណាចបុណ្យសក្តិ និងមិនទទួលបានយុត្តិធម៌។

## សេចក្តីស្នើកែលម្អ និងមតិស្ថាបនា៖

១. រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសមាជិកអាស៊ានត្រូវធានាសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋដោយបញ្ឈប់សកម្មភាពជ្រៀតជ្រែក គំរាមកំហែង ធ្វើទុកបុកម្នេញពីសំណាក់អាជ្ញាធរតាមរយៈ ប្រព័ន្ធតុលាការ លើប្រជាពលរដ្ឋ សហជីព និងអង្គការសង្គមស៊ីវិលតាមគ្រប់រូបភាព និងបន្តលើកស្ទួយ និងទទួលស្គាល់ពីគុណតម្លៃនៃការចូលរួម និងចលនារបស់ស្ត្រីក្នុងសង្គម។

២. រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសមាជិកអាស៊ានត្រូវមានយន្តការច្បាស់លាស់ក្នុងការលើកម្ពស់ដំណើរការប្រជាធិបតេយ្យ ដោយផ្តល់ឱកាសឲ្យប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងជនងាយរងគ្រោះចូលរួមពេញលេញក្នុងដំណើរការរៀបចំគោលនយោបាយ និងបង្កើតច្បាប់ និងផ្តល់ឱកាសក្នុងការបម្រើមុខងារសាធារណៈដោយសមភាព។ ជាពិសេសរដ្ឋាភិបាលនៃរដ្ឋជាសមាជិកអាស៊ានត្រូវបង្កើតឲ្យមានបរិយាកាសប្រកួតប្រជែងនយោបាយក្នុងប្រទេសរបស់ខ្លួនសម្រាប់គ្រប់ភាគីពាក់ព័ន្ធដោយស្មើភាពគ្នា។

៣. រដ្ឋាភិបាលកម្ពុជា និងរដ្ឋសមាជិកអាស៊ានត្រូវធានានូវសេវាយុត្តិធម៌ពេញលេញដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងជនងាយរងគ្រោះ និងត្រូវខិតខំលុបបំបាត់រាល់ទម្រង់និទណ្ឌភាព ដោយបង្កើន សកម្មភាពប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងវិស័យសាធារណៈ ជាពិសេសវិស័យតុលាការ លុបបំបាត់ឥទ្ធិពលនយោបាយក្នុងវិស័យតុលាការឲ្យមានប្រសិទ្ធិភាព និងបន្តពង្រឹងសមត្ថភាពវិជ្ជាជីវៈដល់មន្ត្រីតុលាការ។

## II. បញ្ហាប្រឈម និងកង្វល់ ធំៗពាក់ព័ន្ធស្ថានភាពការធ្វើជំនួញ វិនិយោគ និងអំណាចសាជីវកម្ម

១. ប្រជាពលរដ្ឋកំពុងប្រឈមមុខនឹងការបាត់បង់ដីធ្លី ព្រៃឈើ ធនធានធម្មជាតិ មុខរបរ ប្រពៃណីទំនៀមទម្លាប់ សិទ្ធិក្នុងបញ្ចេញមតិ និងសិទ្ធិប្រមូលផ្តុំរបស់កសិករ អ្នកនេសាទ ជនជាតិដើមភាគតិច កម្មករជាពិសេស ការកាត់កំលាំងពលកម្ម និងប្រាក់ឈ្នួលដែលជំនួសដោយមនុស្សយន្ត ឬម៉ាស៊ីនស្វ័យប្រវត្តិ យុវជន បានបាត់បង់ការងារធ្វើ និងចំណាកស្រុក និងមិនអាចប្រកួតប្រជែងបាន រីឯអ្នកផលិតខ្នាតតូច និងមធ្យម មិនទទួលបានគាំទ្រ និងមិនអាចប្រកួតប្រជែងជាមួយនឹងផលិតផលនាំចូល និង ខាងក្រៅ ។

២. ការមិនទាន់ទទួលបាននូវសិទ្ធិទទួលបានសេវាសាធារណៈពេញលេញ និងកិច្ចគាំពារសង្គម ដូចជាការអប់រំ សុខាភិបាល ទឹក ភ្លើងដោយហេតុថាសេវាទាំងនេះត្រូវបានគ្រប់គ្រងដោយវិស័យឯកជន។

៣. កិច្ចព្រមព្រៀងពាណិជ្ជកម្ម ភាពជាដៃគូសេដ្ឋកិច្ចថ្នាក់តំបន់ទូលំទូលាយ (RCEP) ដោយប្រទេស នៅក្នុងអាស៊ានជាអ្នកជំរុញ ដោយកិច្ចព្រមព្រៀងនេះនឹងធ្វើឲ្យតួនាទី របស់អ្នកវិនិយោគកាន់តែធំ ដោយអាចប្តឹងរដ្ឋ។ ការដាក់កម្មសិទ្ធិបញ្ញាទៅលើតម្លៃថ្នាំ និងការគម្រាមកំហែងលើកសិករខ្នាតតូច និងស្បៀងអាហារ

(ការគ្រប់គ្រង់គ្រាប់ពូជ) ពឹងផ្អែកទៅលើការនាំចូលក្នុងខណៈលទ្ធភាពក្នុងការនាំចេញនៅមានកម្រិត។ លក្ខខណ្ឌការងារ និងប្រាក់ឈ្នួលសមរម្យមិនទាន់ឆ្លើយតបពេញលេញទៅនឹងតម្រូវការរបស់កម្មករ។

**សេចក្តីស្នើកែលម្អ ឬ មតិស្ថាបនា៖**

១. សេវាសាធារណៈ និងកិច្ចគាំពារសង្គមដែលមានដូចជា ការអប់រំ សុខភាព ទឹក ភ្លើង ទូរគមនាគមន៍ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង់ និងជាតួនាទីរបស់រដ្ឋ ។

២. ពាណិជ្ជកម្មបែបយុត្តិធម៌ និងស្មើភាព មានយន្តការគាំពាររបស់រដ្ឋក្នុងការគាំទ្រដល់កសិករ និងអ្នកប្រកបរបរខ្នាតតូច និងមធ្យម និងកំណត់កូតាសម្រាប់ផលិតផលនាំចូលដោយធានានូវគុណភាព និងសុវត្ថិភាព។ រដ្ឋត្រូវមានច្បាប់ក្នុងការគ្រប់គ្រង់ទំនិញក្នុងទីផ្សារ។ ធ្វើការវិនិយោគផ្ទាល់ជាមួយកសិករដោយមិនយកដីរបស់ប្រជាជនធ្វើជាសម្បទាន និងធានាថាកសិករមានអំណាច ក្នុងការគ្រប់គ្រងទៅលើតម្លៃ និងផលិតផល កសិកម្ម។

៣. ដើម្បីធានាប្រជាធិបតេយ្យបែបចូលរួម រដ្ឋត្រូវធ្វើការបង្ហាញ និងពិគ្រោះយោបល់ជាមួយប្រជាជន និងសហគមន៍ រាល់កិច្ចព្រមព្រៀងវិនិយោគនានា (ដូចជា RCEP) និងបង្ហាញអំពីជំហររបស់ខ្លួនទៅលើអត្ថប្រយោជន៍ និងផលប៉ះពាល់ដល់សាធារណៈជនឲ្យបានច្បាស់លាស់ ។

**III. បញ្ហាប្រឈម និងកង្វល់ធំៗពាក់ព័ន្ធស្ថានភាពសន្តិភាព និងសុវត្ថិភាព**

១. ប្រជាពលរដ្ឋមានក្តីបារម្ភចំពោះការប្រែប្រួលនៃស្ថានភាពនយោបាយដែលមានការរិតត្បិតលំហរនៃការចូលរួមរបស់ពួកគាត់ក្នុងផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម ជាពិសេសលើរឿងការរំលោភបំពានដីធ្លី សិទ្ធិសេរីភាព បញ្ចេញមតិគ្រប់រូបភាពរួមទាំងតាមរយៈសិល្បៈ ការប្រមូលផ្តុំ និងប្រព័ន្ធផ្សព្វផ្សាយ។ ប្រជាពលរដ្ឋមានភាពភ័យ ខ្លាចក្នុងការរាយការណ៍ពីអំពើខុសច្បាប់ និងបញ្ចេញមតិដោយសារការគម្រាមកំហែងគ្រប់រូបភាព។

២. បញ្ហានៃការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង និងអំពើហិង្សាកើតមានឡើងនៅស្ទើរតែគ្រប់សហគមន៍ដែលធ្វើឲ្យប្រជាពលរដ្ឋមានភាពភ័យខ្លាចក្នុងការរស់នៅប្រចាំថ្ងៃ ប៉ះពាល់ដល់ការរីកលូតលាស់ សុវត្ថិភាព និងសន្តិសុខក្នុងភាពជាមនុស្ស ជាពិសេសលើកុមារ យុវជន និងស្ត្រី ហើយជាពិសេសអាជ្ញាធរមូលដ្ឋានមិនមានយន្តការច្បាស់លាស់ណាមួយក្នុងការទប់ស្កាត់ការជួញដូរគ្រឿងញៀន។ ចំណែកគ្រឿងស្រវឹងវិញត្រូវបានលើកទឹកចិត្តគ្រប់រូបភាពទាំងការផ្សព្វផ្សាយ និងការផ្តល់ជារង្វាន់ផ្សេងៗ។

៣. ការនាំចូលផលិតផល ចំនីអាហារ បន្លែ ផ្លែឈើពីប្រទេសជិតខាង បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សុវត្ថិភាពចំណីអាហាររបស់ប្រជាពលរដ្ឋ ដែលធ្វើឲ្យសុខមាលភាពសង្គមមានការធ្លាក់ចុះ។

៤. ការធូរលុងតាមច្រកព្រំដែន បណ្តាលឲ្យមានអន្តោប្រវេសន៍ខុសច្បាប់ បង្កើតឲ្យមានការរស់នៅអាណាធិបតេយ្យ បញ្ហាព្រំដែនរវាងប្រទេសជិតខាង បណ្តាលឲ្យកើតមានឡើងអសន្តិសុខ និងអសុវត្ថិភាពរបស់ប្រជាពលរដ្ឋនៅតាមបណ្តាយព្រំដែន។

**សេចក្ដីស្នើកែលម្អ ឬមតិស្លាបនោះ**

១. រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធត្រូវមានយន្តការក្នុងការបើកលំហរសិទ្ធិសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ជាពិសេសយុវជន គ្រប់រូបភាព តាមរយៈការពិនិត្យឡើងវិញនូវគោលនយោបាយ បទដ្ឋានគតិយុត្តិមួយចំនួនដែលមានស្រាប់ និងផ្សព្វផ្សាយគោលការណ៍មូលដ្ឋានគ្រឹះនៃសិទ្ធិសេរីភាព និងប្រជាធិបតេយ្យនេះឲ្យគ្រប់ភាគីយល់ និងអនុវត្តឲ្យមានប្រសិទ្ធិភាពទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ លំហរសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋក្នុងការចូលរួមវិស័យនយោបាយដោយមិនមានភាពភ័យខ្លាចត្រូវធានាដោយច្បាប់ និងការអនុវត្តរបស់រាជរដ្ឋាភិបាលដោយរួមបញ្ចូលទាំងការបញ្ឈប់ការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ និងកងសន្តិសុខសណ្ដាប់ធ្នាប់រាជធានី/ខេត្ត ខ័ណ្ឌ/ស្រុក ដើម្បីការពារក្រុមហ៊ុនឯកជនដែលរំលោភសិទ្ធិពលរដ្ឋ។

២. រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ក៏ដូចជាប្រជាពលរដ្ឋផ្ទាល់ត្រូវលើកកម្ពស់ និងជំរុញការផ្សព្វផ្សាយអំពីសន្តិសុខ និងសុវត្ថិភាពសង្គម តាមយន្តការសហគមន៍ និងគ្រួសាររឹងមាំ។ យន្តការនៃការទប់ស្កាត់បញ្ហាគ្រឿងញៀនត្រូវតែផ្ដោតសំខាន់ក្នុងទប់ស្កាត់ និងចាត់វិធានការឲ្យមានប្រសិទ្ធិភាពលើការជួញដូរ ហើយយន្តការទប់ស្កាត់តាមសហគមន៍ដោយអាជ្ញាធរមូលដ្ឋានត្រូវតែមានការបញ្ច្រៀបការអប់រំសហគមន៍ ជាពិសេសផ្ដោតលើការធានាសុវត្ថិភាពដល់ស្ត្រី និងកុមារ។ លើសពីនេះទៅទៀត ក្រសួងពាក់ព័ន្ធត្រូវលុបបំបាត់ការផ្សព្វផ្សាយជំរុញការប្រើប្រាស់គ្រឿងស្រវឹងដូចជាការផ្ដល់រង្វាន់ផ្សេងៗ និងសកម្មភាពដទៃទៀតដែលជំរុញដល់ការប្រើប្រាស់គ្រឿងញៀន។

៣. រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធត្រូវតែមានការរិតបន្តឹង ការនាំចូលផលិតផល ចំណីអាហារ បន្លែ ផ្លែឈើ ដោយពិនិត្យយ៉ាងយកចិត្តទុកលើលើសុវត្ថិភាពចំណីអាហារដែលអាចធ្វើឲ្យប៉ះពាល់ដល់សុខមាលភាពប្រជាពលរដ្ឋ ជាពិសេសលើកកម្ពស់ការប្រើប្រាស់ និងផ្ដល់តម្លៃផលិតផលក្នុងស្រុក និងគាំទ្រកសិកម្មក្នុងស្រុកដោយផ្ដល់នូវការបណ្ដុះបណ្ដាលបច្ចេកទេស និងធនធានផ្សេងៗដែលត្រូវការ។

## IV. បញ្ហាប្រឈម និងកង្វល់ ធំៗពាក់ព័ន្ធស្ថានភាពចំណាកស្រុកក្រៅប្រទេស

១. ពលករចំណាកស្រុកត្រូវចំណាយថវិកាច្រើនក្នុងដំណើរការ និងនីតិវិធីស្មុគស្មាញក្នុងការស្នើសុំឯកសារស្របច្បាប់ដើម្បីបានទៅធ្វើការនៅក្រៅប្រទេស។ ពួកគេត្រូវខ្ចីបុលពីអ្នកផ្ដល់កម្ចីរួមមាន មីក្រូហិរញ្ញវត្ថុ និងធនាគារជាដើមដែលជាហេតុជំរុញឲ្យពលរដ្ឋជំពាក់បំណុលដែលអត្រាការប្រាក់ខ្ពស់។

២. នៅពេលពលករចំណាកស្រុកទៅដល់ប្រទេសគោលដៅ ពួកគេជួបប្រទះបញ្ហាប្រឈមផ្សេងៗរួមមានបញ្ហាសុខភាព ការមិនទទួលបានកិច្ចគាំពារសង្គម បរិស្ថានការរស់នៅ និងត្រូវគេជួញដូរកំលាំងពលកម្មជួញដូរមនុស្ស និងការរំលោភបំពានសិទ្ធិគ្រប់រូបភាព ជាពិសេសពួកគេធ្លាក់ខ្លួនក្លាយជាទាសភាពក្នុងសម័យ ទំនើបក្នុងស្ថានភាពការងារដូចជាស្ត្រីបំរើការងារតាមផ្ទះ ពលករនេសាទ និងការងារសំណង់នៅប្រទេសមួយ ចំនួនដូចជាប្រទេសថៃ និងប្រទេសម៉ាឡេស៊ី។

៣. នៅពេលពលករត្រឡប់មកមាតុប្រទេសវិញ ពួកគេមិនទទួលបានឱកាសប្រើប្រាស់ជំនាញដែលធ្លាប់បានបម្រើការងារនៅក្រៅប្រទេស ដើម្បីអាចទទួលបានការងារធ្វើ និងរកប្រាក់ចំណូលចិញ្ចឹមជីវភាពនោះទេ ទើបពួកគេត្រូវបង្ខំចិត្តចំណាកស្រុកសាជាថ្មី។

## សេចក្តីស្នើកែលម្អ ឬមតិស្ថាបនា៖

១. រដ្ឋាភិបាលកម្ពុជាត្រូវតែបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈតាមមូលដ្ឋាន និងផ្តល់វគ្គបណ្តុះបណ្តាលខ្លី ស្តីពីជំនាញការងារមុនពេលធ្វើចំណាកស្រុកដោយឥតគិតថ្លៃដល់ពលករចំណាកស្រុក និងត្រូវបង្កើតគណៈកម្មាធិការប្រឹក្សាយោបល់ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនៅតាមមូលដ្ឋាន ដើម្បីជួយសម្រួល ដល់ដំណើរការរកងារធ្វើនៅក្រៅប្រទេសដល់ពលរដ្ឋក្នុងមូលដ្ឋាន។ ចំពោះពលករចំណាកស្រុកខ្លួនឯងក៏ត្រូវ ចេះស្វែងរកព័ត៌មានឲ្យបានច្បាស់លាស់មុននឹងធ្វើចំណាកស្រុក ជាពិសេសត្រូវសុំប្រឹក្សាយោបល់ពីស្ថាប័ន ដែលធ្វើការលើវិស័យចំណាកស្រុក។ រដ្ឋាភិបាលកម្ពុជាត្រូវតែកំណត់តម្លៃសេវារកការងារធ្វើរបស់ភ្នាក់ងារជ្រើសរើសពលករ និងតម្លៃឯកសារស្របច្បាប់ផ្សេងៗឲ្យទាបសមរម្យ និងត្រូវកំណត់រយៈនៃការរង់ចាំចេញដំណើរទៅធ្វើការមិនលើសពី៣ ទៅ៤ ខែគិតចាប់ពីថ្ងៃដាក់ពាក្យសុំទៅធ្វើការ។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលត្រូវតែចេញអនុក្រឹត្យស្តីពីតម្លៃសេវាកម្មរកការងារ និងនីតិវិធីទៅធ្វើការនៅបរទេសឲ្យបានច្បាស់លាស់ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់សាធារណៈជន។

២. រដ្ឋាភិបាលនៃប្រទេសបញ្ជូន និងប្រទេសទទួលត្រូវពង្រឹងការអនុវត្តយន្តការការពារ (ប្រកាស អនុក្រឹត្យ ច្បាប់ គោលនោបាយជាតិស្តីទេសន្តរប្រវេសន៍ និងលិខិតបទដ្ឋានគតិយុត្តិអន្តរជាតិ ជាដើម) ដែលមានស្រាប់ដើម្បី ការពារ ពលករចំណាកស្រុកទាំងមានឯកសារ និងមិនមានឯកសារឲ្យមានប្រសិទ្ធភាព និងត្រូវធានា ផ្តល់នូវសេវាយុត្តិធម៌ និងលុបបំបាត់និទណ្ឌភាពលើពលករចំណាកស្រុក និងការស្តារនីតិសម្បទាក្នុងករណីដែលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍មកប្រទេសកំណើតវិញ។ រដ្ឋាភិបាលនៃប្រទេសទទួល ត្រូវធានា និងការពារពលករចំណាកស្រុកឲ្យទទួលបាននូវអត្ថប្រយោជន៍នានាស្របតាមការងារដូចកម្មករនៃប្រទេសរបស់ខ្លួនដែរ។

៣. រដ្ឋាភិបាលប្រទេសកម្ពុជាត្រូវតែបិទអាជីវកម្មរបស់ភ្នាក់ងារជ្រើសរើសពលករទៅក្រៅប្រទេស និងផ្តន្ទាទោសម្ចាស់ក្រុមហ៊ុន/មេខ្យល់ នោះឲ្យបានធ្ងន់ធ្ងរ និងប្រកបដោយប្រសិទ្ធភាព នៅពេលពួកគេប្រព្រឹត្តខុស។

## V. បញ្ហាប្រឈម និងកង្វល់ធំៗពាក់ព័ន្ធស្ថានភាពការងារសមរម្យ សុខភាព និងការគាំពារសង្គម

១. នៅកម្ពុជាមានសិប្បកម្មតូចៗ និងគ្រឹះស្ថានសេវាកម្សាន្តមិនបានចុះបញ្ជីជាច្រើនកំពុងធ្វើអាជីវកម្ម ដែលការនេះអាចនាំឲ្យម្ចាស់អាជីវកម្មរំលោភ មិនគោរពច្បាប់ការងារ កម្មករមិនទទួលបានរបបសន្តិសុខសង្គម មិនមានកិច្ចសន្យាការងារស្របតាមច្បាប់ជាធរមាន។ ចំពោះកម្មករ កម្មការិនីកម្មកររោងចក្រកាត់ដេរដែលប្រើប្រាស់កិច្ចសន្យារយៈពេលខ្លីមិនមានប្រាក់ខែសមរម្យ ដោយហេតុថាត្រូវដេរស៊ីប៉ុងជាដើម។ បញ្ហាសុវត្ថិភាពការងារសម្រាប់ស្ត្រីទាំងវិស័យក្នុង និងក្រៅប្រព័ន្ធនៅតែគ្មានការលើកកម្ពស់ឲ្យស្របនឹងស្តង់ដារសុវត្ថិភាពការងារ (ឧ.សន្តិសុខខណ្ឌចាប់អ្នកប្រកបរបរផ្លូវភេទរាល់ថ្ងៃ និងបញ្ជូនទៅមណ្ឌលព្រៃស្គី) ដែលជា ហេតុនៃការរំលោភបំពានសិទ្ធិស្ត្រីក្នុងវិស័យប្រកបរបរការងារ។

២. ការផ្តល់សេវាសុខភាព និងសេវាសាធារណៈជាទូទៅ មិនទាន់មានការយកចិត្តទុកដាក់ខ្ពស់ ដោយនៅមានការរើសអើង ទៅលើស្ត្រីប្រកបរបរផ្លូវភេទ អ្នករត់រ៉ឺម៉កកង់បី (តុក១) និងអ្នកប្រកបមុខរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។
៣. ប្រាក់ឈ្នួលគោល និងកម្រៃទទួលបានរបស់កម្មករ កម្មការិនីរោងចក្រ សហគ្រាសនៅវិស័យក្នុង និងក្រៅប្រព័ន្ធមិនឆ្លើយតបទៅនឹងការរស់នៅសមរម្យប្រចាំថ្ងៃដោយសារ តម្លៃទំនិញ តម្លៃផ្ទះជួល ទឹក ភ្លើងឡើងថ្លៃ ទៅតាមការតម្លើងរបស់ម្ចាស់អាជីវកម្ម និងម្ចាស់ផ្ទះជួល។

### សេចក្តីស្នើកែលម្អ ឬមតិស្ថាបនាៈ

១. ស្នើរសុំឲ្យរាជរដ្ឋាភិបាលត្រូវត្រួតពិនិត្យគ្រឹះស្ថាន សិប្បកម្ម និងគ្រឹះស្ថានសេវាកម្សាន្តដែលមិនចុះបញ្ជីឡើងវិញ និងចាត់វិធានការសមស្រប ដើម្បីឲ្យមានការធានា នូវការគោរព និងអនុវត្តច្បាប់ការងារ ក៏ដូចជាការធានាសុវត្ថិភាពក្នុងពេលបំពេញការងារ ដល់កម្មករទាំងវិស័យក្នុង និងក្រៅប្រព័ន្ធ។ ធានាសិទ្ធិស្ត្រីប្រកបរបរផ្លូវភេទ ទទួលបាននូវការការពារសិទ្ធិពេញលេញដោយធានានូវសុវត្ថិភាពការងារ ដោយពិនិត្យទៅលើការអនុវត្តច្បាប់បង្ក្រាបការជួញដូរ និងអាជីវកម្មផ្លូវភេទ និងភូមិ ឃុំ មានសុវត្ថិភាព ស្របតាមបទដ្ឋានអន្តរជាតិ ស្តីពីសិទ្ធិស្ត្រី។ ពិនិត្យឡើងវិញច្បាប់ស្តីពីការជួញដូរមនុស្ស (មាត្រា២៤ និង២៥) និងអាជីវកម្មផ្លូវភេទ។
២. រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធពង្រឹងសេវាសាធារណៈ ដែលក្នុងនោះរួមមានសេវាសុខភាពជាដើម្បីលុបបំបាត់ការរើសអើង ចំពោះការទទួលបានសេវាសុខភាពសាធារណៈ និងធានាថាមានការផ្តល់សេវាមិនគិតថ្លៃ ដែលមានគុណភាព ដល់ជនក្រីក្រ និងក្រុមងាយរងគ្រោះ។
៣. រាជរដ្ឋាភិបាលត្រូវគ្រប់គ្រងតម្លៃទំនិញមូលដ្ឋាន ដោយកំណត់តម្លៃទំនិញទីផ្សារឲ្យបានសមរម្យ ដើម្បីធានាឲ្យកម្មករ និងប្រជាជនក្រីក្រ ក៏ដូចជាដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋទូទៅអាចរស់នៅសមរម្យ។

### VI. បញ្ហាប្រឈម និងកង្វល់ធំៗពាក់ព័ន្ធស្ថានភាពនិរន្តភាពប្រព័ន្ធអេកូឡូស៊ី

១. ការរំលោភយកដីធ្លីរបស់រដ្ឋពីបុគ្គល (ប្រជាជនខ្លួនឯង) ក្រុមអ្នកមានអំណាច និងក្រុមហ៊ុនវិនិយោគដោយកាប់បំផ្លាញនូវព្រៃឈើជាទ្រង់ទ្រាយធំសម្រាប់ធ្វើអាជីវកម្ម ឬទន្ទ្រានដីព្រៃកាន់កាប់សម្រាប់យកដីលក់ ដោយមាននិទណ្ឌភាពខ្ពស់។ ការកាប់រានឈូសឆាយដីដុតបំផ្លាញព្រៃលិចទឹកនៅតំបន់ទន្លេសាប និងការកាប់រានយកដីព្រៃកោងកាងនៅតំបន់ឆ្នេរធ្វើកម្មសិទ្ធិ សម្រាប់បង្កបង្កើតផលកសិកម្មផ្ទាល់ខ្លួន និងប្រើឧបករណ៍នេសាទចាប់ត្រីខុសច្បាប់ស្តីពីជលផលទាំងនៅតំបន់មេគង្គ តំបន់ឆ្នេរ និងតំបន់ទន្លេសាប ទង្វើទាំងអស់នេះនឹងបណ្តាលឲ្យមានផលប៉ះពាល់ដល់ស្ថានភាព និងនិរន្តរភាពប្រពន្ធ័អេកូឡូស៊ី។
២. ការកសាងទំនប់វារីអគ្គិសនីនៅលើតួមេទន្លេមេគង្គ និងដៃទន្លេ នៅក្នុងអាងទន្លេមេគង្គលើ (ក្នុងប្រទេសចិន) និងក្នុងអាងទន្លេមេគង្គក្រោម រួមមាន ឡាវ វៀតណាម និងកម្ពុជាជាដើម បង្កឲ្យមានផលប៉ះពាល់ដល់លំនៅដ្ឋាន ដីកសិកម្ម ដំណាំ ទ្រព្យសម្បត្តិ ជីវភាព វប្បធម៌ និងអាយុជីវិតរបស់ប្រជាជនដែលរស់នៅតាមដងទន្លេ (បង្កឲ្យមានការបណ្តេញចេញ) និងការខូចខាតដល់ប្រព័ន្ធអេកូឡូស៊ីទឹកទន្លេទាំងមូលរួម

មានការរាំងខ្ទប់ដីល្បាប់ និងការបម្លាស់ទីរបស់ត្រី ប៉ះពាល់ដល់ការពងកូនរបស់ត្រី ដែលធ្វើឲ្យធ្លាក់ចុះជីវម៉ាស់ត្រី នាំឲ្យប៉ះពាល់ដល់សន្តិសុខស្បៀង និងបរិមាណ និងគុណភាពទឹកទន្លេមេគង្គ។
៣. ការគ្រប់គ្រង និងប្រើប្រាស់ កែច្នៃ សំណល់-សំរាម ជាពិសេសសំណល់ផ្លាស្ទីកមិនបានល្អ ដែលមានការដុតនូវសំណល់-សំរាមទាំងនោះដែលបង្កការបំពុលដល់គុណភាពខ្យល់ និងបរិស្ថាន។

**សេចក្តីស្នើកែលម្អ ឬមតិស្ថាបនា៖**

១. រដ្ឋាភិបាលកម្ពុជាគួរជំរុញការចុះបញ្ជីដីជាប្រព័ន្ធ និងសមូហភាពសហគមន៍ជនជាតិដើមភាគតិច និងជូនប្រជាពលរដ្ឋទូទៅ។ ស្នើឲ្យរដ្ឋាភិបាលពន្លឿនយន្តការបង្កើតផែនទីគម្របព្រៃឈើកម្ពុជា ពិនិត្យ និងស៊ើបអង្កេតឡើងវិញនូវការផ្តល់សម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនឯកជននៅក្នុងតំបន់ដែនអភិរក្ស។ គ្រប់គ្រងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចឲ្យបានតឹងរឹង ជំរុញឲ្យមានការប្រើប្រាស់ដីសម្បទាន ស្របតាមគោលការណ៍ច្បាប់។ ធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានឲ្យបានគ្រប់ជ្រុងជ្រោយ និងពិគ្រោះយោបល់ដោយមានការចូលរួមពេញលេញពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ ចំពោះរាល់គម្រោងអភិវឌ្ឍនីមួយៗ។ ពង្រឹងការអភិរក្ស និងការពារធនធានព្រៃឈើឲ្យបានម៉ឺងម៉ាត់ តាមរយៈការពង្រឹងការអនុវត្តច្បាប់ឲ្យបានតាំងរ៉ឹង ដាក់ទោសចំពោះជនដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ និងបំផ្លាញធនធានធម្មជាតិ បរិស្ថានដោយគ្មាននិទណ្ឌភាព។ បណ្តុះគំនិតឲ្យប្រជាជនស្រលាញ់ព្រៃឈើតាមរយៈការអប់រំ និងប្រព័ន្ធផ្សព្វផ្សាយ និងបង្កើនការច្នៃប្រឌិតចំពោះ ការទាញផលពីព្រៃឈើដើម្បីបង្កើតចំណូលជូនប្រជាពលរដ្ឋមូលដ្ឋាន អភិរក្សបរិស្ថានតាមរយៈការបង្កើតតំបន់អេកូទេសចរណ៍ជីវៈចម្រុះធម្មជាតិដែលក្នុងនោះរួមទាំងតំបន់អេកូទេសចរណ៍ ដើម្បីកាត់បន្ថយការកាប់បំផ្លាញ ព្រៃឈើពីប្រជាជនមូលដ្ឋានក្រោមហេតុផលបំពេញជីវភាព។ ការបង្កើតអេកូទេសចរណ៍ជីវៈចម្រុះធម្មជាតិ ដោយមានយន្តការ និងគោលការណ៍ណែនាំជាក់លាក់ជុំវិញការកំណត់ និងការគ្រប់គ្រងតំបន់អេកូទេសចរណ៍ ដោយធានាថាអេកូទេសចរណ៍បង្កើតឡើង ដើម្បីធានាប្រយោជន៍ ការពារព្រៃឈើ ជីវៈចម្រុះ និងសហគមន៍មូលដ្ឋាន។
២. បញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនីនានា ជាពិសេសនៅលើតួមេទន្លេមេគង្គ ដោយបន្ត និងបន្ថែមការយកចិត្តទុកដាក់លើថាមពលកកើតឡើងវិញដែលស្អាត (ថាមពលពន្លឺព្រះអាទិត្យ និងថាមពលខ្យល់) ដោយ ស្នើសុំឲ្យរដ្ឋាភិបាលលើកកម្ពស់ការផលិត ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ទាំងខ្នាតធំ មធ្យម និងតូចតាមខ្នងផ្ទះ ដើម្បីឆ្លើយតបនឹងកំណើននៃតម្រូវការថាមពលនាពេលបច្ចុប្បន្ន។ រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណាកែប្រែ និងជំរុញការប្រើប្រាស់ដីសម្បទានសេដ្ឋកិច្ចមួយផ្នែក យកទៅសាងសង់ថាមពលពន្លឺព្រះអាទិត្យ ព្រមទាំងជំរុញយន្តការសន្សំសំចៃ និងប្រសិទ្ធិភាពការប្រើប្រាស់ថាមពល តាមសហគ្រាសក្រុមហ៊ុន និងតាមគេហដ្ឋាននីមួយៗ។ រដ្ឋាភិបាលអាស៊ានគួររួមគ្នាស្នើទៅរដ្ឋាភិបាលចិន ឲ្យធ្វើការសិក្សានូវផលប៉ះពាល់ជាបណ្តុំនៃគម្រោងទំនប់វារីអគ្គិសនីរបស់ខ្លួនដែលបានសង់រួច និងកំពុងសាងសង់ ចំពោះប្រទេសដែលនៅខ្សែទឹកខាងក្រោម។
ចំពោះគម្រោងអគ្គិសនីដែលកំពុងសាងសង់ រដ្ឋាភិបាលត្រូវធ្វើការត្រួតពិនិត្យដំណើរនៃការអនុវត្តគម្រោងរបស់ទំនប់វារីអគ្គីសនីដើម្បីធានានូវបទដ្ឋានសុវត្ថិភាព និងការគោរពយន្តការកាត់បន្ថយផលប៉ះពាល់

ចំពោះសង្គម និងបរិស្ថាន។ បន្តដោះស្រាយរាល់ផលប៉ះពាល់នៃគម្រោងអគ្គិសនីដែលកំពុងសាងសង់ និងបានបញ្ចប់ការសាងសង់ ដោយបន្តដោះស្រាយជីវភាពរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ផ្តល់ឲ្យពួកគេនូវសំណងសមរម្យដែលអាចស្តារជីវភាពរបស់ពួកគាត់បានដូចដើម ឬប្រសើរជាងមុន។ ព្រមទាំងបង្កើតនូវគោលការណ៍ណែនាំគោលនយោបាយសំណងថ្នាក់ជាតិឲ្យបានសមរម្យ និងយុត្តិធម៌ដល់ប្រជាជន និងសហគមន៍ដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍ ជាជាងការប្រើប្រាស់យន្តការដោះស្រាយផលប៉ះពាល់ម្តងមួយគម្រោងៗ ដាច់ដោយឡែក ដោយគ្មានបទដ្ឋានស្តង់ដា ការកំណត់គោលការណ៍ណែនាំពីសំណងច្បាស់លាស់។ រដ្ឋាភិបាលកម្ពុជាត្រូវយកចិត្តទុកដាក់នូវបញ្ហារបស់ស្ត្រី និងកុមារ ធានាថាពួកគេមិនទទួលរងគ្រោះ ឬបណ្តេញចេញដោយបង្ខំពីផ្ទះសម្បែង និងសហគមន៍ ដើម្បីទាញយកធនធានធម្មជាតិ និងកសាងទំនប់វារីអគ្គិសនីធំក្នុងប្រទេសឡើយ។

ម្យ៉ាងវិញទៀត រដ្ឋាភិបាលកម្ពុជា និងអាស៊ានត្រូវបន្ថែមការយកចិត្តទុកដាក់ចំពោះបញ្ហាសង្គម និងជាពិសេស បញ្ហាបរិស្ថាន ជាជាងការយកចិត្តទុកដាក់តែទៅលើផ្នែកសេដ្ឋកិច្ចជ្រុលហួសហេតុ ដែលធ្វើឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់មនុស្ស និងបរិស្ថាន ជាពិសេសធនធានធម្មជាតិរបស់កម្ពុជា និងអាស៊ានរងនូវការបំផ្លាញ និងបាត់បង់ នាំមកនូវផលប៉ះពាល់ដល់អនាគត និងសុខមាភាពអ្នកជំនាន់ក្រោយ។ រដ្ឋសមាជិកអាស៊ានគួរបន្ថែម "បរិស្ថាន" ជាសរសរស្តម្ភមួយទៀតរបស់អាស៊ានដើម្បីធានាការយកចិត្តទុកដាក់យ៉ាងពេញលេញលើផ្នែកនេះ។

៣. អប់រំផ្សព្វផ្សាយប្រជាពលរដ្ឋឲ្យមានការផ្លាស់ប្តូរគំនិត ឥរិយាបថនៃការប្រើប្រាស់ថង់ប្លាស្ទិក និងវេចខ្ចប់ សំរាម ដោយមានផែនការគ្រប់គ្រងការប្រើប្រាស់ថង់ប្លាស្ទិក បង្កើនទីកន្លែងគ្រប់គ្រង និងចាក់កាកសំណល់នៅ ទីប្រជុំជននីមួយៗ ព្រមទាំងបង្កើនសេវាដឹកជញ្ជូន និងគ្រប់គ្រងកាកសំណល់ និងសំរាមឲ្យមានប្រសិទ្ធិភាពខ្ពស់។ ទន្ទឹមគ្នានេះផងដែររដ្ឋាភិបាលគួរជំរុញ លើកកម្ពស់ការបង្កើតសហគ្រាសកែច្នៃកាកសំណល់ និងសំរាមដោយបង្កើនការលើកទឹកចិត្តការវិនិយោគ លើគម្រោងកែច្នៃកាកសំណល់ និងសំរាមនេះ។ រដ្ឋាភិបាលកម្ពុជា ត្រូវតែគិតគូរដើម្បីទប់ស្កាត់ឲ្យមានប្រសិទ្ធិភាពនូវការបំពុលបរិស្ថាន ការបំពុលទឹក ការបំពុលក្នុងបរិយាកាស និងការគ្រប់គ្រងសំរាម ធានាថាប្រជាពលរដ្ឋទទួលបានសិទ្ធិរស់នៅក្នុងបរិស្ថានល្អ។

## VII. បញ្ហាប្រឈម និងកង្វល់ ធំៗពាក់ព័ន្ធស្ថានភាពការច្នៃប្រឌិត បច្ចេកវិទ្យាថ្មី និងកំពុងរីកចំរើន និងសិទ្ធិទាក់ទងនឹងសិទ្ធិឌីជីថល

១. ប្រជាពលរដ្ឋសម្តែងក្តីព្រួយបារម្ភអំពីសន្តិសុខទិន្នន័យ សុវត្ថិភាពនៃព័ត៌មានឯកជនលើអ៊ីនធឺណែត និង ឧបករណ៍បច្ចេកវិទ្យាថ្មី ខណៈដែលច្បាប់នាពេលបច្ចុប្បន្នខកខានក្នុងការធានា និងការពារសិទ្ធិអ្នកប្រើប្រាស់អ៊ីនធឺណែត បច្ចេកវិទ្យាថ្មី និងសិទ្ធិនានាទាក់ទងនឹងបច្ចេកវិទ្យា ។

២. អ្នកអនុវត្តន៍សិទ្ធិសេរីភាពបញ្ចេញមតិ និងសិទ្ធិពាក់ព័ន្ធនានាតាមប្រព័ន្ធអ៊ីនធឺណែតត្រូវបានចោទប្រកាន់ ចាប់ខ្លួន និងផ្តន្ទាទោស ដែលការណ៍នេះធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តន៍សិទ្ធិមូលដ្ឋានដែលត្រូវ

បានធានាដោយលិខិតូបករណ៍អន្តរជាតិដែលក្នុងនោះរួមមាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ល។

៣. មានការភ័យខ្លាចក្នុងការបញ្ចេញមតិ ចែករំលែកព័ត៌មាន ឬព័ត៌មានក្លែងក្លាយ និងលំហរសេរីភាពផ្សេងៗតាមតាមអ៊ីនធឺណែត ដោយសារតែកន្លងមកមានការចោទប្រកាន់ ចាប់ខ្លួន គំរាមកំហែងនិងផ្តន្ទាទោសដោយមិនបានអនុវត្តវិធានការការពារ និងបទដ្ឋានសិទ្ធិមនុស្សត្រឹមត្រូវ ។

**សេចក្តីស្នើកែលម្អ ឬមតិស្ថាបនា៖**

១. រដ្ឋាភិបាល និងភាគីពាក់ព័ន្ធត្រូវបន្តលើកកម្ពស់ការយល់ដឹងអក្ខរកម្មបច្ចេកវិទ្យាតាមរយៈ ការកំណត់ពន្យល់ពាក្យក្នុងសទ្ទានុក្រមដោយមាននិយមន័យច្បាស់លាស់ ក្រមសីលធម៌ និងវិធីសាស្ត្រ ធានាសុវត្ថិភាពទិន្នន័យ វាយតម្លៃព័ត៌មាន និងព័ត៌មានឯកជនឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋទូទៅដើម្បីឲ្យពួកគេបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

២. រដ្ឋាភិបាលត្រូវបង្កើតច្បាប់សន្តិសុខទិន្នន័យដើម្បីការពារទិន្នន័យអ្នកប្រើប្រាស់អ៊ីនធឺណែត និងបច្ចេកវិទ្យាថ្មីៗដែលតម្រូវឲ្យក្រុមហ៊ុនឯកជន អ្នកផ្តល់សេវា ក្រុមហ៊ុនសាជីវកម្មពាណិជ្ជកម្មតាមអ៊ីនធឺណែត អាជ្ញាធរសាធារណៈ ឬភាគីពាក់ព័ន្ធផ្សេងៗដែលមានកាតព្វកិច្ចត្រូវការពារសន្តិសុខ ទិន្នន័យសុវត្ថិភាពនៃព័ត៌មានឯកជន និងឧបករណ៍បច្ចេកវិទ្យាថ្មីៗ ។

៣. រដ្ឋាភិបាលត្រូវបើកលំហរសេរីភាព ធានា និងលើកកម្ពស់សិទ្ធិក្នុងការប្រើប្រាស់អ៊ីនធឺណែត និងបច្ចេកវិទ្យាថ្មីដល់ប្រជាពលរដ្ឋឲ្យបានទូលំទូលាយដោយអនុលោមតាមលិខិតូបករណ៍អន្តរជាតិដែលការពារសិទ្ធិមនុស្ស ស្ត្រី ។ ល ។ ក្នុងនោះរួមមាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ល។

យើងសង្ឃឹមយ៉ាងមុតមាំថា សម្លេង និងសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋត្រូវបានគោរពពេញលេញ និងកង្វល់របស់យើងត្រូវបានដោះស្រាយ ដើម្បីធានាថារាល់ការអភិវឌ្ឍ និងគោលនយោបាយរបស់អាស៊ានទាំងអស់ពិតជាបានទុកប្រយោជន៍ប្រជាពលរដ្ឋជាធំ។ អ្នកតាក់តែង អ្នកអនុវត្តគោលនយោបាយ និងប្រមុខ ថ្នាក់ដឹកនាំកម្ពុជា និងរដ្ឋសមាជិកអាស៊ានត្រូវតែរួមគ្នាស្វែងរកនូវដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព ស្របតាមគោលការណ៍មិនទុកនរណាម្នាក់ចោលឡើយ ដើម្បីធានានូវការរស់នៅរបស់ប្រជាជនកម្ពុជា ក៏ដូចជាប្រជាតិអាស៊ានប្រកបដោយសេចក្តីថ្លៃថ្នូរ និងវិបុលភាព។

**ព័ត៌មានបន្ថែមសូមទាក់ទង៖**


១. កញ្ញា សេង រាសី ទូរស័ព្ទលេខ និងSignal: ០១៧ ៩៣៣ ៣៣៦ អ៊ីមែល: reaseys@silaka.org

២. លោក សៀន ប៊ុនរិទ្ធ ទូរស័ព្ទលេខ និងSignal: ០១១ ៥៣៥ ៣៥៤ អ៊ីមែល: seanbunrith@comfrel.org

៣. លោកស្រី អេង ចាន់ឌី ទូរស័ព្ទលេខ និងSignal: ០១០ ២៧០ ០០០ អ៊ីមែល: anm@gadc.org.kh